ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសកម្មករនិយោជិតគ្រប់ជំនាញនៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ

ដោយមានការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតឱកាសការងារជូនប្រជាពលរដ្ឋ សំដៅលើកកម្ពស់ជីវភាព និងសុខមាលភាពឱ្យកាន់តែល្អប្រសើរ តាមរយៈគោលនយោបាយនិងយន្តការនានា ដើម្បីទាក់ទាញការវិនិយោគ ជាពិសេសការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅតាមបណ្តារាជធានី-ខេត្តនានា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់ សាធារណជន កម្មករនិយោជិត អង្គការវិជ្ជាជីវៈ និងនិយោជកឱ្យបានជ្រាបថា បច្ចុប្បន្នតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុមានសហគ្រាសឧស្សាហកម្មនិងសេវាកម្មចំនួន៩៣ ដែលបានផ្តល់ការងារជូនប្រជាពលរដ្ឋជាង១៣.០០០នាក់។ ក្នុងត្រីមាសទី១ ឆ្នាំ២០១៦ នេះ ដោយសារមានការកើនឡើងជាលំដាប់នៃការវិនិយោគ ក៏ដូចជាការពង្រីកវិសាលភាពចង្វាក់ផលិតកម្មសហគ្រាស គ្រឹះស្ថានជាច្រើននៅក្នុងតំបន់សេដ្ឋកិច្ចក្រុងព្រះសីហនុត្រូវការជ្រើសរើសកម្មករ និងបុគ្គលិកជំនាញជាច្រើន មានដូចខាងក្រោម៖

| | |
|---|---|
| ១-កម្មករធម្មតាចំនួន | ១.០០០នាក់ |
| ២-អ្នកបកប្រែចិន-ខ្មែរចំនួន | ៦៨នាក់ |
| ៣-កម្មករជំនាញកាត់ដេរចំនួន | ៤០០នាក់ |
| ៤-កម្មករធ្វើម៉ាស៊ីនចំនួន | ១៥០នាក់។ |

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងទីភ្នាក់ងារជាតិមុខរបរ និងការងារ អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរសព្ទលេខ ០២៣ ៦៣៣ ៦០០២, ០៧៧ ២៣២ ៣៧៨, ០១៦ ៧៨៦ ៦៥៥ ឬតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ អាសយដ្ឋាន ផ្លូវជាតិលេខ៤ គីឡូម៉ែត្រ២១២ សង្កាត់ព្រៃនប់ ខេត្តកំពង់សោម ទូរសព្ទលេខ ០៣៤ ៦៨៦០ ០៨៦។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម សាធារណជន កម្មករនិយោជិត អង្គការវិជ្ជាជីវៈ និងនិយោជកមេត្តាជ្រាបជាព័ត៌មាន និងជួយផ្សព្វផ្សាយដល់អ្នកដែលកំពុងស្វែងរកការងារធ្វើ។

*រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦*



Scanned by CamScanner